ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ: ៧៥ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង**

**កម្មវត្ថុ ៖** របាយការណ៍ស្ដីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥។

**យោង ៖** -របាយការណ៍ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន **០៧ ក្រុមហ៊ុន** ក្នុងខេត្តស្ទឹងត្រែង រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**I-ក្រុមហ៊ុន (ខេមបូឌា) រីស៊ើច ម៉ាញនីង ឌីវេឡុបមេន** (CAMBODIA) RESEARCH MINING DEVELOPMENT Co.,Ltd

១-និភាករណ៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **(ខេមបូឌា) រីស៊ើច ម៉ាញនីង ឌីវេឡុបមេន** (CAMBODIA) RESEARCH MINING DEVELOPMENT Co.,Ltd ។

២-និភាករណ៍លិខិតលេខ **៨៩៩ សជណ** ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៨ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ដែលអនុញ្ញាតជាគោលការណ៍ដល់ក្រុមហ៊ុន **(ខេមបូឌា) រីស៊ើច ម៉ាញនីង ឌីវេឡុបមេន** (CAMBODIA) RESEARCH MINING DEVELOPMENT Co.,Ltd សម្រាប់វិនិយោគដាំកៅស៊ូ និងដាំឈើ លើផ្ទៃដីទំហំ **៧.២០០** (ប្រាំពីរពាន់ពីររយ) ហិកតា មានទីតាំងស្ថិតនៅក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង និងសិទ្ធិប្រទានលេខ **៥៧.សប្រទ** ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល និងនិភាករណ៍កិច្ចសន្យា ស្ដីពីការវិនិយោគដាំកៅស៊ូ និងដាំឈើ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន (ខេមបូឌា) រីស៊ើច ម៉ាញនីង ឌីវេឡុបមេន

(CAMBODIA) RESEARCH MINING DEVELOPMENT Co.,Ltd ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ សម្រាប់រយៈពេល **៧០ (ចិតសិប) ឆ្នាំ**។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តស្ទឹងត្រែង គ្រប់គ្រង។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**II-ក្រុមហ៊ុន បូណារីតា ស្ទឹងត្រែង**

១-កែសម្រួលផ្ទៃដីគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **បូណារីតា ស្ទឹងត្រែង** មានទីតាំងនៅស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ពីទំហំ **៨៦៩ (ប្រាំបីរយហុកសិបប្រាំបួន) ហិកតា** មកជា ទំហំ **៤២៦ (បួនរយម្ភៃប្រាំមួយ) ហិកតា** និងកែសម្រួលរយៈពេលវិនិយោគពី **៩៦ (កៅសិបប្រាំមួយ) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងបន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តស្ទឹងត្រែង និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **បូណារីតា ស្ទឹង ត្រែង** ឡើងវិញឱ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តស្ទឹងត្រែង គ្រប់គ្រង។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**III-ក្រុមហ៊ុន សុក ហេង ខមភេនី លីមីធីត**

១-និរាករណ៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **សុក ហេង ខមភេនី លីមីធីត**។

២-និរាករណ៍លិខិតលេខ **៤៣២ សជណ.កស** ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ដែលរាជរដ្ឋាភិបាលបានសម្រេចលុបគោលការណ៍ និងកិច្ចសន្យាវិនិយោគសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **សុក ហេង ខមភេនី លីមីធីត** លើផ្ទៃដីចំនួន **៧.១៧២ (ប្រាំពីរពាន់មួយរយចិតសិបពីរ) ហិកតា** ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ទុកជាសម្បត្តិរដ្ឋវិញ ដោយទុកតែដីដែលបានដាំដុះរួចហើយចំនួន **៦២០ (ប្រាំមួយរយម្ភៃ) ហិកតា** ប៉ុណ្ណោះសម្រាប់ឱ្យក្រុមហ៊ុនធ្វើវិនិយោគបន្ត និងសិទ្ធិប្រទានលេខ **១០១.សប្រទ** ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល និងនិរាករណ៍កិច្ចសន្យាស្ដីពីការវិនិយោគដាំដើមអាកាស្យា និងប្រភេទឈើផ្សេងៗទៀត និងសាងសង់រោងចក្រកែច្នៃក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន **សុក ហេង ខមភេនី លីមីធីត** ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ សម្រាប់រយៈពេល **៧០ (ចិតសិប) ឆ្នាំ**។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តស្ទឹងត្រែង គ្រប់គ្រង។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសដើម្បីគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**IV-ក្រុមហ៊ុន អ៊ុន-អ៊ិនធើរ ត្រេឌីង & ឌីវេឡុបមេនគ្រុប (ខេមបូឌា)** UN-INTER TRADING & DEVEL OPMENT GROUP (CAMBODIA) Co.,Ltd

១-និរាករណ៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **អ៊ុន-អ៊ិនធើរ ត្រេឌីង & ឌីវេឡុបមេនគ្រុប (ខេមបូឌា)** UN-INTER TRADING & DEVEL OPMENT GROUP (CAMBODIA) Co.,Ltd ។

២-និរាករណ៍លិខិតលេខ **៩០០ សជណ** ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រីដែលអនុញ្ញាតជាគោលការណ៍ដល់ក្រុមហ៊ុន **អ៊ុន-អ៊ិនធើរ ត្រេឌីង & ឌីវេឡុបមេនគ្រុប (ខេមបូឌា)** UN-INTER TRADING & DEVEL OPMENT GROUP (CAMBODIA) Co.,Ltd សម្រាប់វិនិយោគដាំកៅស៊ូ និងដាំឈើ លើផ្ទៃដីទំហំ **៧.០០០ (ប្រាំពីរពាន់) ហិកតា** ដែលមានទីតាំងស្ថិតនៅក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង និងសិទ្ធិប្រទានលេខ **៥៨.សប្រទ** ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល និងនិរាករណ៍កិច្ចសន្យា ស្តីពីការវិនិយោគដាំដំណាំកៅស៊ូ និងដាំឈើ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន **អ៊ុន-អ៊ិនធើរ ត្រេឌីង & ឌីវេឡុបមេនគ្រុប (ខេមបូឌា)** UN-INTER TRADING & DEVEL OPMENT GROUP (CAMBODIA) Co.,Ltd ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ សម្រាប់រយៈពេល **៧០ (ចិតសិប) ឆ្នាំ**។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តស្ទឹងត្រែងគ្រប់គ្រង។

**V-ក្រុមហ៊ុន** GREEN SEA INDUSTRY Co., LTD (GREEN SEA AGRICULTURE Co., LTD)

១-កែសម្រួលផ្ទៃដីគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន GREEN SEA INDUSTRY Co., LTD (GREEN SEA AGRICULTURE Co., LTD) មានទីតាំងនៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ពីទំហំ **១០០.៨៥២ (មួយរយពាន់ប្រាំបីរយហាសិបពីរ) ហិកតា** មកជាទំហំ **៩.៨០០ (ប្រាំបួនពាន់ប្រាំបីរយ) ហិកតា** និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងបន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តស្ទឹងត្រែង និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន GREEN SEA INDUSTRY Co., LTD (GREEN SEA AGRICULTURE Co., LTD) ឡើងវិញឱ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តស្ទឹងត្រែងគ្រប់គ្រង។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**VI-ក្រុមហ៊ុន ផលិតម្សៅដំឡូងមីចំកាត់**

១-កែសម្រួលផ្ទៃដីគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ផលិតម្សៅដំឡូងមីចំកាត់** ស្ថិតនៅក្នុងស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ពីទំហំ **៧.៤០០ (ប្រាំពីរពាន់បួនរយ) ហិកតា** មកជាទំហំ **២.៩៦៥**

(ពីរពាន់ប្រាំបួនរយហុកសិបប្រាំ) ហិកតា និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា **៥០ (ហាសិប) ឆ្នាំ** និងបន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តស្ទឹងត្រែង និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ផលិតម្សៅដំឡូងមីចំកាត់** ឡើងវិញឱ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តស្ទឹងត្រែង គ្រប់គ្រង។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**VII-ក្រុមហ៊ុន GG WORLD GROUP ( CAMBODIA ) DEVELOPMENT .Ltd**

១-កែសម្រួលផ្ទៃដីគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន GG WORLD GROUP (CAMBODIA) DEVELOPMENT .Ltd ស្ថិតនៅក្នុងស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ពីទំហំ **៥.០០០ (ប្រាំពាន់) ហិកតា** មកជាទំហំ **២.២០០ (ពីរពាន់ពីររយ) ហិកតា** និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងបន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយទើបចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តស្ទឹងត្រែង និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន GG WORLD GROUP (CAMBODIA) DEVELOPMENT .Ltd ឡើងវិញឱ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តស្ទឹងត្រែង គ្រប់គ្រង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**គាវ៉េត សំរេច**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងបរិស្ថាន
-ក្រសួងរ៉ែ និងថាមពល
-អង្គភាពប្រឆាំងអំពើពុករលួយ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ឯកសារ-កាលប្បវត្តិ